# ការតាមដានអវត្តមានគ្រូបង្រៀននាំឱ្យមានការកែលម្អដល់វត្តមានសិស្ស និងឱកាសអប់រំល្អប្រសើរសម្រាប់ពួកគេ


© Nicolas Axelrod / Ruom / CARE

សិស្សសាលាបឋមសិក្សា ដាក់ដាំ ក្នុងខេត្តមណ្ឌលគិរី ទទួលអត្ថប្រយោជន៍ពីការអប់រំ ដែលមានគុណភាពដោយសារវត្តមានរបស់គ្រូបង្រៀនមានភាពល្អប្រសើរច្រើន។

នៅពេលសួរថា ហេតុអ្វីនាងចូលចិត្តរៀននៅសាលាបឋមសិក្សាដាក់ដាំ ក្នុងខេត្តមណ្ឌលគិរី កុមារីអាយុ ១៤ឆ្នាំ ឈ្មោះ ប៊ុន្នី កាស្រី តបថា នាងចូលចិត្តការសិក្សា និងចូលចិត្តលេងជាមួយមិត្តភក្តិរបស់នាង។ នៅពេលអនាគតនាងចង់ក្លាយជាវេជ្ជបណ្ឌិត ឬភ្នាក់ងារសុខភាព។

ក្មេងស្រីជនជាតិភាគតិចព្នងម្នាក់នេះមានចិត្តចង់រៀនសូត្រណាស់ នាងមិនធ្លាប់អវត្តមានមួយថ្ងៃទេ។ ជាអកុសលគ្រូដែលបង្រៀននាងកាលពីឆ្នាំមុនមិនសូវមកបង្រៀនទេ។

នាងនិយាយថា ៖ "ឆ្នាំមុនខ្ញុំបានរៀនជាមួយគ្រូម្នាក់គាត់មិនសូវជាមកបង្រៀនទេ"។ នាងពន្យល់ដោយក្តីរីករាយថាក្នុងឆ្នាំសិក្សានេះ ស្ថានភាពនេះបានប្រែប្រួលយ៉ាងខ្លាំង។

អង្គការឃែរកម្ពុជាបាន និងកំពុងគាំទ្រសាលាបឋមសិក្សាដាក់ដាំ អស់រយៈពេលពីរឆ្នាំមកហើយតាមរយៈវគ្គបណ្តុះបណ្តាលស្តីពីការគ្រប់គ្រងសាលារៀន និងទំនាក់ទំនងសាលារៀនជាមួយសហគមន៍។ ក្នុងផ្នែកមួយនៃវគ្គបណ្តុះបណ្តាលសមាជិក
គណៈកម្មការត្រូវបានបង្រៀនអំពីការតាមដានវត្តមានគ្រូ និងសិស្ស និងតាមដានរកមូលហេតុនៃអវត្តមានរបស់ពួកគេ។

ព្យុយ ផាន្នី ជាអនុប្រធានភូមិ ពូត្រាង និងជាសមាជិកគណៈកម្មការទ្រទ្រង់សាលារៀននិយាយថា គាត់បានដឹងអំពីការទទួលខុសត្រូវរបស់ខ្លួនតាមរយៈវគ្គបណ្តុះបណ្តាលមួយរបស់អង្គការឃែរ ដែលសម្របសម្រួលដោយបុគ្គលិកការិយាល័យអប់រំស្រុក។ ស្ត្រីវ័យ ៤២ឆ្នាំរូបនេះបញ្ជាក់ថា ៖ "កាលពីមុនខ្ញុំមិនបានដឹងអំពីតួនាទីរបស់គណៈកម្មការទ្រទ្រង់សាលាទេ" ។

[គាត់បន្តថា] ៖ "ឥឡូវក្នុងនាមជាសមាជិកគណៈកម្មការទ្រទ្រង់សាលារៀន ខ្ញុំតាមដានគ្រូជាពិសេសនៅពេលពួកគេអវត្តមានច្រើន ខ្ញុំត្រូវដឹងពីមូលហេតុដែលពួកគេអវត្តមាន។ ហើយបន្ទាប់ពីខ្ញុំបានដឹងពីមូលហេតុនៃអវត្តមានរបស់ពួកគេ ខ្ញុំក៏ប្រាប់នាយកសាលាអំពីអវត្តមានរបស់ពួកគេ"។

គាត់មកមើលសាលារៀនជាទៀងទាត់ ដើម្បីតាមដានគ្រូ និងសិស្ស និងដើម្បីប្រាកដថាកុមាររៀននៅសាលាបឋមសិក្សាដាក់ដាំ ទទួលបានការអប់រំដែលមានគុណភាព។ គាត់ពន្យល់ថា ៖ "គ្រូបានចាប់ផ្តើមយកចិត្តទុកដាក់ចំពោះសិស្ស និងវត្តមានសិស្សរបស់ពួកគេ ព្រោះឥឡូវពួកគេដឹងថាមានគេកំពុងតាមដានពួកគេ"។

> *"ឆ្នាំមុនខ្ញុំបានរៀនជាមួយគ្រូម្នាក់ គាត់មិនសូវជាមកបង្រៀនទេ។ ឆ្នាំនេះខុសពីឆ្នាំមុន"។*

ចាស់ ផលទ្បែន អាយុ២៦ឆ្នាំ ដែលជាគ្រូបង្រៀននៅសាលាបឋមសិក្សាដាក់ដាំ ទទួលស្គាល់បញ្ហានេះ និងភាពប្រសើរឡើងនូវវត្តមានរបស់គ្រូបង្រៀន។

អ្នកគ្រូនិយាយថា ៖ "ពីមុនយើងមានបញ្ហាជាមួយនឹងវត្តមានគ្រូ។ តែឥឡូវមិនដូចពីមុនទេ។ តាំងពីការបង្កើតគណៈកម្មការទ្រទ្រង់សាលារៀន និងការប្រជុំជាសាធារណៈជាមួយឪពុកម្តាយមក ពួកគេអាចលើកពីបញ្ហាដែលកំពុងកើតមានឡើងនៅសាលារៀន វត្តមានគ្រូក៏ផ្លាស់ប្តូរ"។

គាត់ដឹងពីបញ្ហាទាក់ទនឹងវត្តមានគ្រូនេះច្រើនជាងអ្នកៗណាទាំងអស់ ពីព្រោះគាត់ពីមុនធ្លាប់អវត្តមានដែរ។ អ្នកគ្រូវ័យក្មេងរូបនេះសារភាពថា ៖ "ពេលខ្លះខ្ញុំខកខានមិនបានទៅបង្រៀនទេ ព្រោះខ្ញុំត្រូវជួយឪពុករបស់ខ្ញុំនៅឯស្រែចម្ការ។ តែឥឡូវនេះ ដោយសារគណៈកម្មការទ្រទ្រង់សាលាកំពុងតាមដានវត្តមានគ្រូ ដូច្នេះខ្ញុំមកបង្រៀនទៀងទាត់"។

**These activities are part of the *School Governance* project, which is supported by the Capacity Development Partnership Fund.**

សហភាពអឺរ៉ុប SWEDEN unicef

មូលនិធិភាពជាដៃគូសម្រាប់អភិវឌ្ឍសមត្ថភាពវិស័យអប់រំ (CDPF)

© CARE Cambodia, September 2016